ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# សេចក្តីណែនាំស្តីពី ការអនុវត្តន៍យុទ្ធនាការជាតិ

## ក្រោមប្រធានបទ

# "រួមគ្នាទទួលខុសត្រូវទប់ស្កាត់ការ ចម្លងវីរុសកូវីដ-១៩ "

**យើងកំពុងស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់ជាមួយគ្នា**

**យើងរួមគ្នាប្រយុទ្ធនឹងជំងឺកូវីដ-១៩ ជាមួយគ្នា!**

Guidelines on the Implementation of National Campaigns

Under the heading

**"Together be responsible to stop COVID-19 transmission"**

'We are in this together- We will overcome COVID-19 together'


រៀបចំដោយ៖

អនុគណៈកម្មការអប់រំ បណ្តុះបណ្តាល
និងទំនាក់ទំនងសាធារណៈនៃគណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹង
ជំងឺកូវីដ-១៩

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសុខាភិបាល
លេខ ៣៦៣ អស១៧

**រដ្ឋមន្ត្រីក្រសួងសុខាភិបាល និងជាប្រធាន**
**គណៈកម្មការអន្តរក្រសួង ដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩**
**ជម្រាបជូន**
**ឯកឧត្តម លោកជំទាវ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួង ស្ថាប័នពាក់ព័ន្ធ**
**ឯកឧត្តម លោកជំទាវ អភិបាលនៃគណៈអភិបាលរាជធានី-ខេត្តទាំង ២៥**

**កម្មវត្ថុ ៖** អនុវត្តយុទ្ធនាការ អប់រំ ផ្សព្វផ្សាយ និងបណ្តុះបណ្តាលប្រជាពលរដ្ឋ ក្រោមប្រធានបទ ***"រួមគ្នាទទួលខុសត្រូវទប់ស្កាត់ការចម្លងវីរុសកូវីដ-១៩"*** ដើម្បីជំរុញការទទួលខុសត្រូវរបស់បុគ្គល គ្រួសារ សហគមន៍ ស្ថាប័នពាក់ព័ន្ធជាពិសេសសេវាឯកជន អាជ្ញាធរមូលដ្ឋាន រួមគ្នាទទួលខុសត្រូវក្នុងស្មារតីសាមគ្គីភាព ដើម្បីកាត់ផ្តាច់ខ្សែចម្លងវីរុសកូវីដ-១៩ ព្រមទាំង រស់នៅជាមួយនឹងវីរុសកូវីដ-១៩ តាមគន្លងប្រកតីភាពថ្មីឲ្យបានត្រឹមត្រូវ។

**យោង ៖** សេចក្តីណែនាំអំពីការងារមួយចំនួនពាក់ព័ន្ធនឹងការអនុវត្តផែនការយុទ្ធសាស្ត្រចាក់វ៉ាក់សាំងកូវីដ-១៩ និងការរៀបចំ"យុទ្ធនាការអនុវត្តយុទ្ធសាស្ត្រ ៦ ចំណុចរបស់ **សម្តេចតេជោ នាយករដ្ឋមន្ត្រី** សំដៅទប់ស្កាត់រលកទី៣ នៃការឆ្លងរាលដាលជំងឺកូវីដ-១៩ និងដើម្បីត្រៀមខ្លួនរស់ជាមួយជំងឺកូវីដ-១៩ ក្នុងគន្លងប្រក្រតីភាពថ្មី"របស់ **គណៈប្រចាំការនៃគណៈកម្មការជាតិប្រយុទ្ធនឹងជំងឺកូវីដ-១៩** (**គបក**)។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន ឯកឧត្តម លោកជំទាវ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួង ស្ថាប័នពាក់ព័ន្ធ ឯកឧត្តម លោកជំទាវ អភិបាលនៃគណៈអភិបាលរាជធានី-ខេត្តទាំងអស់ជ្រាបថា យុទ្ធនាការអនុវត្តយុទ្ធសាស្ត្រ ៦ ចំណុចរបស់ **សម្តេចតេជោ នាយករដ្ឋមន្ត្រី** សំដៅទប់ស្កាត់រលកទី៣ នៃការឆ្លងរាលដាលជំងឺកូវីដ-១៩ និងដើម្បីត្រៀមខ្លួនរស់ជាមួយជំងឺកូវីដ-១៩ ក្នុងគន្លងប្រក្រតីភាពថ្មីកំពុងតែដំណើរការយ៉ាងសកម្ម ដើម្បីទប់ស្កាត់ស្ថានភាពរាតត្បាតនៃជំងឺកូវីដ-១៩។ ទន្ទឹមនឹងនេះដើម្បីទាក់ទាញប្រជាពលរដ្ឋឲ្យបង្កើនការយកចិត្តទុកដាក់ខ្ពស់ឡើងវិញក្នុងការប្រកាន់ខ្ជាប់នូវវិធានការសុវត្ថិភាពផ្នែកសុខាភិបាល ជាពិសេសវិធានការ " **៣ការពារ និង៣កុំ**" ព្រមទាំងផ្លាស់ប្តូរឥរិយាបថ ដើម្បីរៀនរស់នៅជាបណ្តើរៗជាមួយនឹងវត្តមាននៃមេរោគកូវីដ-១៩ គណៈកម្មការអន្តរក្រសួងប្រយុទ្ធនឹងជំងឺកូវីដ-១៩ បានដាក់ចេញនូវ លិខិតចុះថ្ងៃទី២៦ ខែកក្កដាកន្លងមក ស្តីពីការអនុវត្តយុទ្ធនាការទូទាំងប្រទេស ដើម្បីអប់រំ ផ្សព្វផ្សាយ និងបណ្តុះបណ្តាលប្រជាពលរដ្ឋឲ្យយល់ដឹងអំពីគ្រោះថ្នាក់នៃវីរុសកូវីដ-១៩ ដែលត្រូវបន្តជាប់ជាប្រចាំដោយស្មារតីយកចិត្តទុកដាក់ខ្ពស់ ។



ទីស្តីការក្រសួងសុខាភិបាល ដីឡូតិ៍លេខ ៨០ វិថីសម្តេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៨៨៥ ៩៧០/៨៨៤ ៩០៩

យុទ្ធនាការអប់រំផ្សព្វផ្សាយអំពីវិធានការការពារជំងឺកូវីដ-១៩បានធ្វើឡើងយ៉ាងច្រើនក្នុងរយៈពេលកន្លងមក។ ប៉ុន្តែសកម្មភាពទាំងអស់នោះមិនទាន់គ្រប់គ្រាន់សម្រាប់ឆ្លើយតបទៅនឹងស្ថានភាពនៃការចម្លងវីរុសកូវីដ-១៩នាបច្ចុប្បន្ន។ ដូច្នេះការរៀបចំបន្តយុទ្ធនាការដែលមានលក្ខណៈផ្តោតចំពោះ និងមានកិច្ចសហការរវាងភាគីពាក់ព័ន្ធទាំងអស់ ដោយល្អិតល្អន់ និងសម្រុកក្នុងពេលតែមួយចាប់ពីពេលនេះតទៅគឺមានសារៈសំខាន់បំផុត ដើម្បីឈានទៅសម្រេចបានការផ្លាស់ប្តូរឥរិយាបថរបស់ប្រជាជនក្នុងការរស់នៅតាមបែបគន្លងថ្មីជាមួយ វីរុសកូវីដ-១៩ ។ ជាមួយគ្នានេះ អនុគណៈកម្មការអប់រំ បណ្តុះបណ្តាល និងទំនាក់ទំនងសាធារណៈ នៃគណៈកម្មការអន្តរក្រសួងប្រយុទ្ធនឹងជំងឺកូវីដ-១៩ ក៏បានរៀបចំជាសេចក្តីណែនាំក្នុងការរៀបចំយុទ្ធនាការអប់រំ ផ្សព្វផ្សាយ និងបណ្តុះបណ្តាលប្រជាពលរដ្ឋ ក្រោមប្រធានបទ ***"រួមគ្នាទទួលខុសត្រូវទប់ស្កាត់ការចម្លងវីរុសកូវីដ-១៩"*** (ដូចជូនភ្ជាប់មកជាមួយ) ដើម្បីជាមគ្គុទេសជំនួយបន្ថែមក្នុងការរៀបចំអនុវត្តយុទ្ធនាការថ្នាក់ជាតិនេះឲ្យកាន់តែមានប្រសិទ្ធភាព។

អាស្រ័យហេតុនេះ សូមឯកឧត្តម លោកជំទាវ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី អភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត មេត្តាចូលរួមជំរុញយុទ្ធនាការពញ្ញាក់ស្មារតីសាមគ្គីភាព និងការទទួលខុសត្រូវរបស់ភាគីពាក់ព័ន្ធក្រោមសមត្ថកិច្ចរបស់ឯកឧត្តម លោកជំទាវ និងបុគ្គលគ្រប់រូប ក្នុងការចូលរួមទប់ស្កាត់ការចម្លងវីរុសកូវីដ-១៩ ដោយរៀបចំសកម្មភាពសំខាន់ៗតាមសេចក្តីណែនាំយុទ្ធនាការនេះដោយស្មារតីទទួលខុសត្រូវខ្ពស់។

សូមឯកឧត្តម លោកជំទាវ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី អភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត ទទួលនូវការគោរព និងស្រឡាញ់រាប់អានដ៏ជ្រាលជ្រៅពីខ្ញុំ។

ថ្ងៃចន្ទ ៩រោច ខែទុតិយាសាឍ ឆ្នាំឆ្លូវ ទោស័ក ព.ស ២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី០២ ខែសីហា ឆ្នាំ២០២១

**រដ្ឋមន្ត្រីក្រសួងសុខាភិបាល និងជាប្រធាន**
**គណៈកម្មការអន្តរក្រសួង ដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩**

**ម៉ម ប៊ុនហេង**



ទីស្តីការក្រសួងសុខាភិបាល ដីឡូត៍លេខ ៨០ វិថីសម្តេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩

# មាតិកា


**មាតិកា**..........2

**អារម្ភកថា**..........4

**១. សេចក្តីផ្តើម**..........6

**២. អ្វីដែលយើងបាននិងកំពុងធ្វើ**..........10

**៣. ទិដ្ឋភាពរួមរបស់យុទ្ធនាការ**..........12

ក. ក្រុមគោលដៅ..........12

ខ. គោលបំណងនៃឥរិយាបថ..........12

គ. ឧបសគ្គរាំងស្ទះក្នុងការផ្លាស់ប្តូរឥរិយាបថ..........13

ឃ. កត្តាជំរុញលើកទឹកចិត្តក្នុងការផ្លាស់ប្តូរឥរិយាបថ..........15

ង. សារគន្លឹះសម្រាប់យុទ្ធនាការ..........16

**៤. យុទ្ធសាស្រ្តក្នុងការអនុវត្តន៍យុទ្ធនាការ**..........17

ក. យុទ្ធសាស្រ្តទី១៖ ទំនាក់ទំនងអន្តរបុគ្គល..........17

ខ. យុទ្ធសាស្រ្តទី២៖ ការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ..........18

**៥. សកម្មភាពយុទ្ធនាការ**..........20

ក. សកម្មភាពយុទ្ធនាការថ្នាក់ជាតិ..........20

ខ. សកម្មភាពយុទ្ធនាការនៅរាជធានី-ខេត្ត..........20

គ. សកម្មភាពយុទ្ធនាការពីស្ថាប័នពាក់ព័ន្ធក្រសួងប្រៃសណីយនិងទូរគមនាគមន៍ ៖ បណ្តាញសង្គម និងទូរស័ព្ទ..........22

ឃ. សកម្មភាពយុទ្ធនាការពីស្ថាប័នពាក់ព័ន្ធ ក្រសួងព័ត៌មាន៖ ប្រព័ន្ធផ្សព្វផ្សាយ..........22

ង. សកម្មភាពយុទ្ធនាការពី ស្ថាប័នពាក់ព័ន្ធ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ..........22

ច. សកម្មភាពយុទ្ធនាការពីស្ថាប័នពាក់ព័ន្ធ៖ ស្ថាប័នអប់រំ..........23

ឆ. រៀបចំការបិទតាំង និងវត្ថុអនុស្សាវរីយ៍..........23

**៦. សម្ភារសម្រាប់យុទ្ធនាការ**..........23

**៧. ការត្រួតពិនិត្យ តាមដាន និងវាយតម្លៃ**..........23

***៨. ផែនការសកម្មភាពក្នុងការអនុវត្តន៍យុទ្ធនាការ*** ........ 25
***៩. ផែនការផ្សព្វផ្សាយសារ*** ........ 28
***១០. ឧបសម្ព័ន្ធ*** ........ 29
*ឧបសម្ព័ន្ធទី១៖ សម្ភារដែលនឹងផលិតបន្ថែម* ........ 29
*ឧបសម្ព័ន្ធទី២៖ ទ្រឹស្តីផ្លាស់ប្តូរឥរិយាបថ* ........ 34

# អារម្ភកថា

ប្រទេសកម្ពុជាកំពុងវិវឌ្ឍន៍ទៅកាន់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ទ្រង់ទ្រាយធំក្នុងសហគមន៍ ដែលជាបន្ទុកធំលើសសមត្ថភាពប្រព័ន្ធប្រពោធនកម្មសម្រាប់ការព្យាបាលធ្ងន់ធ្ងរ (ICU) ប្រសិនបើពុំមានការដាក់ចេញ និងអនុវត្តជាបន្ទាន់នូវយុទ្ធសាស្ត្រដែលមានប្រសិទ្ធភាពបន្ថែមនោះទេ ។ វីរុសកូវីដ-១៩ កំពុងចរាចរក្នុងចំណោមប្រជាពលរដ្ឋ និងមានករណីឆ្លងក្នុងចំណោមបុគ្គលិកសុខាភិបាល ករណីធ្ងន់ធ្ងរ និងស្លាប់កំពុងកើនឡើងផងដែរ ។ ដូច្នេះហើយ ដើម្បីទប់ស្កាត់ការចម្លងវីរុស **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានដាក់ចេញនូវយុទ្ធសាស្ត្រ ៦ចំណុច សំដៅទប់ស្កាត់រលកទី៣នៃការឆ្លងរាលដាលជំងឺកូវីដ-១៩ និងដើម្បីត្រៀមខ្លួនរស់ជាមួយជំងឺកូវីដ-១៩ ក្នុងគន្លងប្រក្រតីភាពថ្មី" ។ ក្នុងនោះ គណៈប្រចាំការនៃគណៈកម្មការជាតិប្រយុទ្ធនឹងជំងឺកូវីដ-១៩ (គបក) " បានណែនាំដល់អនុគណៈកម្មការអប់រំ បណ្តុះបណ្តាល និងទំនាក់ទំនងសាធារណៈនៃគណៈកម្មការអន្តរក្រសួងប្រយុទ្ធនឹងជំងឺកូវីដ-១៩ ដើម្បីបើកយុទ្ធនាការទូទាំងប្រទេសដើម្បីអប់រំ ផ្សព្វផ្សាយ និងបណ្តុះបណ្តាលប្រជាពលរដ្ឋឲ្យយល់ដឹងអំពីគ្រោះថ្នាក់នៃវីរុសកូវីដ-១៩ ដែលនៅបន្តមានជាប់ជាប្រចាំ ព្រមទាំងផ្លាស់ប្តូរឥរិយាបថដើម្បីរៀនរស់នៅជាបណ្តើរៗជាមួយនឹងវត្តមាននៃមេរោគកូវីដ-១៩ ។

ការចូលរួមប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ពីសំណាក់បុគ្គលម្នាក់ៗ គ្រួសារនីមួយៗ សហគមន៍ ព្រមទាំងស្ថាប័ន និងវិស័យឯកជន ក្នុងការអនុវត្តន៍វិធានការបង្ការ និងការពារខ្លួនពីមេរោគកូវីដ-១៩ គឺជាកត្តាគន្លឹះដ៏សំខាន់ក្នុងការកាត់បន្ថយការឆ្លងរាលដាលនៃជំងឺកូវីដ-១៩។ ដូច្នេះដើម្បីទាក់ទាញប្រជាពលរដ្ឋឲ្យបង្កើនការយកចិត្តទុកដាក់ខ្ពស់ឡើងវិញក្នុងការប្រកាន់ខ្ជាប់នូវវិធានការសុវត្ថិភាពផ្នែកសុខាភិបាល ជាពិសេសវិធានការ "៣ការពារ និង៣កុំ" គណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩ បានធ្វើការជូនដំណឹងដល់អភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត បន្តជំរុញយុទ្ធនាការអប់រំ ផ្សព្វផ្សាយអំពីវិធានការការពារការចម្លងជំងឺកូវីដ-១៩ ដោយប្រើប្រាស់សារអប់រំសុខភាពដែលបានផលិត ផ្សព្វផ្សាយ និងចែកចាយកន្លងមក។ លើសពីនេះ ដើម្បីជំរុញការផ្លាស់ប្តូរឥរិយាបថរបស់ប្រជាជនឲ្យកាន់តែមានប្រសិទ្ធភាព អនុគណៈកម្មការអប់រំបណ្តុះបណ្តាល និងទំនាក់ទំនងសាធារណៈបានរៀបចំបន្ថែមនូវសេចក្តីណែនាំអនុវត្តយុទ្ធនាការជាតិ **"រួមគ្នាទទួលខុសត្រូវទប់ស្កាត់ការចម្លងវីរុសកូវីដ-១៩"** ដែលយុទ្ធនាការនាពេលនេះផ្តោតខ្លាំងទៅលើការជំរុញការទទួលខុសត្រូវរបស់បុគ្គល គ្រួសារ សហគមន៍ ស្ថាប័នពាក់ព័ន្ធជាពិសេសសេវាឯកជន អាជ្ញាធរមូលដ្ឋាន រួមគ្នាទទួលខុសត្រូវក្នុងស្មារតីសាមគ្គីភាពដើម្បីកាត់ផ្តាច់ខ្សែចម្លងវីរុសកូវីដ-១៩ ។

យុទ្ធនាការអប់រំផ្សព្វផ្សាយអំពីវិធានការការពារជំងឺកូវីដ-១៩ បានធ្វើយ៉ាងច្រើនកន្លងមកហើយ។ ប៉ុន្តែសកម្មភាពទាំងអស់នោះមិនគ្រប់គ្រាន់សម្រាប់ឆ្លើយតបទៅនឹងស្ថានភាពនៃការចម្លងវីរុសកូវីដ-១៩ នាបច្ចុប្បន្ននេះទេ។ ដូច្នេះការរៀបចំយុទ្ធនាការក្នុងទម្រង់ថ្មីដែលមានលក្ខណៈផ្តោតចំពោះ និងតម្រូវឲ្យផ្នែកពាក់ព័ន្ធទាំងអស់សហការរួមគ្នាទទួលខុសត្រូវអនុវត្តដោយល្អិតល្អន់ និងសម្រុកក្នុងពេលតែមួយចាប់ពីពេលនេះតទៅគឺមានសារៈសំខាន់បំផុត ដើម្បីឈានទៅសម្រេចបានការផ្លាស់ប្តូរឥរិយាបថរបស់ប្រជាជនក្នុងការរស់នៅតាមបែបគន្លងថ្មីជាមួយ វីរុសកូវីដ-១៩ ។

សេចក្តីណែនាំនេះគឺជាមគ្គុទេសបង្ហាញអំពីសកម្មភាពសំខាន់ៗបន្ថែមទៀតដែលស្ថាប័នពាក់ព័ន្ធនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិត្រូវធ្វើក្នុងពេលវេលាដ៏សំខាន់នេះ។ មានតែការអនុវត្តយុទ្ធនាការដោយស្មារតីទទួលខុសត្រូវរួមគ្នា និងជាពិសេសការចូលរួមយ៉ាងសកម្ម ពីផ្នែកឯកជន និងអាជ្ញាធរមូលដ្ឋានក្នុងជាជំរុញការអនុវត្តវិធានការសុខាភិបាលនៅតាមសេវាកម្ម ឬមូលដ្ឋានរបស់ខ្លួន ទេ ទើបអាចឈានទៅសម្រេចបាននូវការផ្លាស់ប្តូរឥរិយាបថរបស់ប្រជាជនប្រកបដោយនិរន្តភាព ។

ក្នុងនាមក្រសួងសុខាភិបាល និងអនុគណៈកម្មការអប់រំ បណ្តុះបណ្តាល និងទំនាក់ទំនងសាធារណៈនៃគណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩ ខ្ញុំសូមថ្លែងអំណរគុណដល់ ក្រុមការងារអប់រំ និងទំនាក់ទំនងសាធារណៈដែលបានរៀបចំសេចក្តីណែនាំនេះ ព្រមទាំងអំពាវនាវដល់ស្ថាប័នពាក់ព័ន្ធទាំងអស់ ប្តេជ្ញាជំរុញការអនុវត្តន៍យុទ្ធនាការ"**រួមគ្នាទទួលខុសត្រូវទប់ស្កាត់ការចម្លងវីរុសកូវីដ-១៩**"ប្រកបដោយជោគជ័យ។

ថ្ងៃអាទិត្យ ៨រោច ខែទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥
រាជធានីភ្នំពេញ, ថ្ងៃទី១ ខែសីហា ឆ្នាំ២០២១

**រដ្ឋលេខាធិការ ក្រសួងសុខាភិបាល និងជាប្រធាន**
**អនុគណៈកម្មការអប់រំ បណ្តុះបណ្តាល និងទំនាក់ទំនងសាធារណៈ**

**វេជ្ជបណ្ឌិត ឱ វណ្ណឌីន**

# ១. សេចក្តីផ្តើម




រហូតមកដល់ ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២១ ប្រទេសកម្ពុជារកឃើញករណីជំងឺកូវីដ-១៩ឆ្លងថ្មីសរុប #៦៦៨ នាក់ (ករណីឆ្លងសហគមន៍ :៤២៨ និងអ្នកដំណើរពីបរទេស : ២៤០ និងមានអ្នកជាសះស្បើយ #៨១២ នាក់ ) ។ ដូច្នេះចំនួនករណីជំងឺកូវីដ-១៩សរុបកើន # ៧៦,៥៨៥ នាក់ និងចំនួនអ្នកជាសះស្បើយសរុបកើន #៦៩,៩៨ នាក់ និងអ្នកស្លាប់ថ្មី #២៥នាក់ សរុបអ្នកស្លាប់ #១,៣៧៥នាក់ បើយោងតាមរបាយការណ៍របស់នាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង (CDC) ។ នេះសបញ្ជាក់ថា ប្រទេសកម្ពុជាងាយនឹងឈានទៅរកការផ្ទុះរាតត្បាតនៃជំងឺកូវីដ-១៩ ក្នុងទ្រង់ទ្រាយធំបំផុត (ឆ្លងបន្ទាត់ក្រហម)។ ជាមួយនឹងការបិទបញ្ចប់ការបិទខ្ទប់ ការចាប់ផ្តើមដំណើរការសកម្មភាពសង្គម និងសេដ្ឋកិច្ចបណ្តើរៗ និងការបន្តនូវករណីឆ្លងសហគមន៍ និងការមកដល់នូវវីរុសបំប្លែងថ្មីដែលងាយឆ្លងខ្លាំង ដូច្នេះទាមទារឲ្យមានការអនុវត្តនូវការប្រាស្រ័យទាក់ទង ហានិភ័យ និងការចូលរួមរបស់សហគមន៍ដែលមានប្រសិទ្ធភាពបំផុតឈានទៅធ្វើការផ្លាស់ប្តូរឥរិយាបថដើម្បីទប់ស្កាត់ការចម្លងកូវីដ-១៩ នៅក្នុងការទំនាក់ទំនងសង្គមនានាប្រកបដោយនិរន្តរភាព ។

រហូតមកដល់បច្ចុប្បន្ននេះ មានយុទ្ធនាការផ្លាស់ប្តូរអាកប្បកិរិយាជាច្រើនអំពីជំងឺកូវីដ-១៩ ត្រូវបានអនុវត្តន៍ និងផ្សព្វផ្សាយដល់ប្រជាជនទូទៅតាមរយៈទូរទស្សន៍ វិទ្យុ ការបោះពុម្ពខិត្តបណ្ណ រូបភាពផ្ទាំងធំ និង ប្រព័ន្ធផ្សព្វផ្សាយសង្គម ហើយយុទ្ធនាការទាំងនេះបានផ្តោតសំខាន់លើការប្រាប់ប្រជាជនឲ្យអនុវត្តន៍វិធានការ

សុខាភិបាល ដូចជាលាងដៃ និងការរក្សាគម្លាតសង្គមជាដើម ។ បើទោះបីជាមានការខិតខំប្រឹងប្រែងក្នុងការផ្សព្វផ្សាយ និងចង្អុលបង្ហាញបែបនេះក៏ដោយ ក៏សារមួយចំនួនប្រហែលជាមិនអាចទៅដល់ប្រជាជនមួយចំនួនធំ(នៅជនបទ) ឬក៏ប្រជាជនមួយចំនួននៅតែពិបាកក្នុងការផ្លាស់ប្តូរទម្លាប់ ឬអនុវត្តន៍នូវវិធានការសុខាភិ-បាល ពីព្រោះដោយសារពួកគាត់នៅតែមានផ្នត់គំនិតជាប់ជាមួយនឹងទំនៀមទម្លាប់ប្រពៃណី ជំនឿសាសនា ដែលតម្រូវឲ្យពួកគាត់ទៅវត្ត ទីផ្សារ និងជួបជុំគ្នាកម្មវិធីប្រពៃណី/សាសនាផ្សេងៗ ដែលជាកន្លែងមានហានិភ័យខ្ពស់ក្នុងការចម្លងជំងឺកូវីដ-១៩ ។

ក្នុងស្ថានការគ្រោះថ្នាក់បែបនេះ គណៈប្រចាំការនៃគណៈកម្មការជាតិប្រយុទ្ធនឹងជំងឺកូវីដ-១៩(គបក) បានដាក់ចេញសេចក្តីណែនាំអំពីការងារមួយចំនួនពាក់ព័ន្ធនឹងការអនុវត្តផែនការយុទ្ធសាស្រ្តចាក់វ៉ាក់សាំងកូវីដ-១៩ និងការរៀបចំ “យុទ្ធនាការអនុវត្តន៍យុទ្ធសាស្រ្ត ៦ចំណុចរបស់ សម្តេចតេជោ នាយករដ្ឋមន្រ្តី សំដៅទប់ស្កាត់រលកទី៣ នៃការឆ្លងរាលដាលជំងឺកូវីដ-១៩ និងដើម្បីត្រៀមខ្លួនរស់ជាមួយជំងឺកូវីដ-១៩ ក្នុងគន្លងប្រក្រតីភាពថ្មី” ។

ក្នុងស្ថានការគ្រោះថ្នាក់បែបនេះការចូលរួមប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ពីសំណាក់បុគ្គលម្នាក់ៗ គ្រួសារនីមួយៗ សហគមន៍ ព្រមទាំងស្ថាប័ន និងវិស័យឯកជនក្នុងការអនុវត្តវិធានការបង្ការ និងការពារខ្លួនពីមេរោគកូវីដ-១៩ គឺជាកត្តាគន្លឹះដ៏សំខាន់ក្នុងការកាត់បន្ថយការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ។ ដូច្នេះដើម្បីទាក់ទាញប្រជាពលរដ្ឋឲ្យបង្កើនការយកចិត្តទុកដាក់ខ្ពស់ឡើងវិញក្នុងការប្រកាន់ខ្ជាប់នូវវិធានការសុវត្ថិភាពផ្នែកសុខាភិបាល ជាពិសេសវិធានការ “ ៣ការពារ និង៣កុំ ” គណៈប្រចាំការនៃគណៈកម្មការជាតិប្រយុទ្ធនឹងជំងឺកូវីដ-១៩ បានណែនាំដល់អនុគណៈកម្មការអប់រំ បណ្តុះបណ្តាល និងទំនាក់ទំនងសាធារណៈនៃគណៈកម្មការអន្តរក្រសួងដើម្បីបើកយុទ្ធនាការទូទាំងប្រទេសដើម្បីអប់រំ ផ្សព្វផ្សាយ និងបណ្តុះបណ្តាលប្រជាពលរដ្ឋឲ្យយល់ដឹងអំពីគ្រោះថ្នាក់នៃវីរុសកូវីដ-១៩ ដែលនៅបន្តមានជាប់ជាប្រចាំ ព្រមទាំងផ្លាស់ប្តូរឥរិយាបថដើម្បីរៀនរស់នៅជាបណ្តើរៗជាមួយនឹងវត្តមាននៃមេរោគកូវីដ-១៩ ។

អនុគណៈកម្មការអប់រំ បណ្តុះបណ្តាល និងទំនាក់ទំនងសាធារណៈ បានសហការជាមួយស្ថាប័នពាក់ព័ន្ធដូចជា ក្រសួងព័ត៌មាន ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ក្រសួងយុត្តិធម៌ និងថ្នាក់ក្រោមជាតិ បាននឹងកំពុងរៀបចំយុទ្ធនាការថ្នាក់ជាតិក្នុងការផ្លាស់ប្តូរឥរិយាបថសង្គមតាមរយៈការប្រាស្រ័យទាក់ទងក្រោមប្រធានបទ " **បុគ្គលរួមគ្នាទទួលខុសត្រូវទប់ស្កាត់ការចម្លង វីរុសកូវីដ-១៩** " ដើម្បីពង្រឹងនូវការទទួលខុសត្រូវរបស់បុគ្គលគ្រប់រូប គ្រួសារ សហគមន៍ និងស្ថាប័នចូលរួមដោយស្មារតីសាមគ្គីភាពជាតិក្នុងការរួមចំណែកទទួលខុសត្រូវទប់ស្កាត់ការចម្លងនៃវីរុសកូវីដ-១៩ ជាពិសេសការពញ្ញាក់ស្មារតីទទួលខុសត្រូវរបស់ស្ថាប័ន

ពាក់ព័ន្ធ និងសេវាឯកជន បុគ្គល និងគ្រួសារដែលមានប្រជាជនវ័យចំណាស់ ឬជនងាយរងគ្រោះដែលជាក្រុមហានិភ័យខ្ពស់ ក្នុងការអនុវត្តវិធានការសុខាភិបាល ដើម្បីឆ្លើយតបក្នុងការទប់ស្កាត់ការរីករាលដាលនៃការឆ្លងជំងឺកូវីដ-១៩ ក្នុងសហគមន៍ ។











**គោលបំណងនៃយុទ្ធនាការថ្នាក់ជាតិនេះ គឺដើម្បី៖**

| | |
|---|---|
| ១. បង្កើនការចូលរួមរបស់បុគ្គល គ្រួសារ ជាពិសេសស្ត្រី ក្នុងការអនុវត្តវិធានការ "៣ការពារ និង៣កុំ" | ២. លើកកម្ពស់គុណតម្លៃសង្គម និងសាមគ្គីភាពសង្គម ក្នុងការរួមចំណែកទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ |





| | |
|---|---|
| ៣. បង្កើនការចូលរួមអំពីស្ថាប័នពាក់ព័ន្ធ ជាពិសេសស្ថាប័នឯកជនក្នុងការទទួលខុសត្រូវអនុវត្តន៍វិធានការ NPIs (សេវាកម្មមាន សុវត្ថិភាព ទីកន្លែងធ្វើការមានសុវត្ថិភាព) | ៤. បង្កើនការទទួលខុសត្រូវរបស់អាជ្ញាធរសហគមន៍ ក្នុងការជំរុញការចូលរួមរបស់សហគន៍ ក្នុងការតាមដានការអនុវត្តវិធានការសុខាភិបាល និងអន្តរាគមន៍ផ្សេងៗនៅក្នុងតំបន់ |





# ២. អ្វីដែលយើងបាននិងកំពុងធ្វើ

ចាប់តាំងពីមានការរាតត្បាតនៃជំងឺកូវីដ-១៩ ក្រសួងសុខាភិបាលបានអនុវត្តន៍យុទ្ធសាស្ត្រប្រាស្រ័យទាក់ទងហានិភ័យ និងជំរុញការចូលរួមរបស់សហគមន៍។



*សកម្មភាពសកម្មភាព អប់រំផ្សព្វផ្សាយនៅខេត្តពោធិសាត់ ក្រចេះ រតនគីរី និងស្ទឹងត្រែងខែកក្កដា ឆ្នាំ២០២១*

សកម្មភាពប្រាស្រ័យទាក់ទងហានិភ័យ និងការជំរុញការចូលរួមរបស់សហគមន៍កន្លងមករួមមាន៖

- ការរៀបចំយុទ្ធសាស្ត្រប្រាស្រ័យទាក់ទងហានិភ័យ និងការពង្រឹងសមត្ថភាពមន្ត្រីបង្គោលថ្នាក់ រាជធានី-ខេត្តដើម្បីធ្វើការប្រាស្រ័យទាក់ទងហានិភ័យ ដូចជាការតាមដានព័ត៌មានមិនពិត ការដោះស្រាយពាក្យចចាមអារ៉ាម និងការអប់រំផ្សព្វផ្សាយអំពីវិធានការការពារ និងទប់ស្កាត់ការចម្លងជំងឺកូវីដ-១៩ ។
- ផលិតសម្ភារអប់រំសុខភាព និងធ្វើការបែងចែកសម្ភារដល់រាជធានី-ខេត្ត និងធ្វើការផ្សព្វផ្សាយសារអប់រំសុខភាពតាមរយៈបណ្តាញសង្គម ប្រព័ន្ធផ្សព្វផ្សាយ និងចែកចាយបិទតាំងសារអប់រំសុខភាពក្នុងរាជធានី-ខេត្ត ។
- ជំរុញការចូលរួមរបស់សហគមន៍តាមរយៈការបណ្តុះបណ្តាលដល់អាជ្ញាធរ ស្រុក ឃុំ សង្កាត់ ភូមិ ក្រុមទ្រទ្រង់សុខភាពភូមិ ក្រុមប្រឹក្សាពីគ្រោះយោបល់ស្ត្រី និងកុមារឃុំអំពីជំងឺកូវីដ-១៩ និងគោលការណ៍ណែនាំសម្រាប់អនុវត្តន៍ដើម្បីជំរុញការយកចិត្តទុកដាក់ ការទទួលខុសត្រូវ និងការចូលរួមរបស់សហគមន៍ក្នុងការអប់រំផ្សព្វផ្សាយ និងតាមដានការអនុវត្តវិធានការសុខាភិបាលក្នុងមូលដ្ឋាន
- រាជធានី-ខេត្តបានយកចិត្តទុកដាក់ធ្វើការអប់រំផ្សព្វផ្សាយអំពីវិធានការការពារការចម្លងជំងឺកូវីដ-១៩ ក្នុងសហគមន៍តាមរយៈការផ្សាយតាមឧបករណ៍បំពងសម្លេង ការបិទតាំងរូបភាព ការចុះអប់រំផ្ទាល់ជាដើម ។

សកម្មភាពប្រាស្រ័យទាក់ទងហានិភ័យ និងការជំរុញការចូលរួមរបស់សហគន៍ដ៏សកម្មបានចូលរួមចំណែកទប់ស្កាត់ការចម្លងក្នុងសហគមន៍ក្នុងឆ្នាំ២០២០ កន្លងមក។ ប៉ុន្តែសកម្មភាពអប់រំផ្សព្វផ្សាយហាក់មានសកម្មភាពថយចុះនៅថ្នាក់រាជធានី-ខេត្ត ក្នុងរយៈពេលដើមឆ្នាំ២០២១ ជាមួយនឹងការកើនឡើងនូវការចម្លងក្នុងសហគមន៍ជាបន្តបន្ទាប់ ដោយសារភាពមមាញឹករបស់ថ្នាក់ក្រោមជាតិក្នុងការឆ្លើយតបនឹងការរាតត្បាតនៃជំងឺកូវីដ-១៩ ដូចជាតម្រូវការនូវការធ្វើតេស្ត ការធ្វើចត្តាឡីស័ក និងការព្យាបាលជាដើម ។

ទន្ទឹមនឹងនេះសកម្មភាពផលិត និងផ្សព្វផ្សាយសារអប់រំថ្មីៗនៅតែបន្តដោយមានការផ្សព្វផ្សាយនូវសារអប់រំថ្មីជារៀងរាល់សប្តាហ៍ និងចែកចាយសម្ភារអប់រំដល់រាជធានី-ខេត្ត ជាពិសេសម្ភារអប់រំទាក់ទងនឹងយុទ្ធនាការវ៉ាក់សាំង ។

ដើម្បីឲ្យសកម្មភាពអប់រំផ្សព្វផ្សាយកាន់តែមានភាពសកម្មបន្ថែមទៀត យុទ្ធនាការ " **បុគ្គលរួមគ្នាទទួលខុសត្រូវទប់ស្កាត់ការចម្លងវីរុសកូវីដ-១៩** " និងរៀបចំសកម្មភាពប្រទាក់ក្រឡាគ្នាបន្ថែមទៀតក្នុងគោលបំណងអំពាវនាវដល់បុគ្គលទាំងអស់ឲ្យយល់ដឹងអំពីហានិភ័យនៃជំងឺកូវីដ-១៩ និងការចូលរួមទទួលខុសត្រូវរួមគ្នាប្រកបដោយស្មារតីសាមគ្គីភាពក្នុងពេលវេលាតែមួយ ដើម្បីអាចទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ នេះជាបន្តទៅទៀត ។

# ៣. ទិដ្ឋភាពរួមរបស់យុទ្ធនាការ

## ក. ក្រុមគោលដៅ

យុទ្ធនាការនេះនឹងផ្តោតលើក្រុមគោលដៅមួយចំនួន ដូចខាងក្រោម៖

- **ក្រុមគោលដៅទី១៖** ប្រជាជនកម្ពុជាទាំងអស់ (បុគ្គល និងគ្រួសារ)ជាពិសេសមនុស្សចាស់ និងស្ត្រី។
- **ក្រុមគោលដៅទី២៖** ស្ថាប័នពាក់ព័ន្ធជាពិសេសស្ថាប័នឯកជននានាជាអាទិ៍ ភោជនីយដ្ឋាន ទីផ្សារ សេវាកម្មកំសាន្តផ្សេងៗ សេវាកម្មទេសចរណ៍ មធ្យោបាយធ្វើដំណើរសាធារណៈ ហាងកន្លែងលក់ទំនិញ ទីកន្លែងធ្វើការ វត្តអារាម ទីកន្លែងធ្វើការ រោងចក្រ សហគ្រាសជា ដើម។
- **ក្រុមគោលដៅទី៣៖** អាជ្ញាធរមូលដ្ឋានក្នុងសហគមន៍ ដូចជា អាជ្ញាធរស្រុក ឃុំ ភូមិ ក្រុមទ្រទ្រង់សុខភាពភូមិ ក្រុមប្រឹក្សាពីគ្រោះយោបល់ស្ត្រី និងកុមារឃុំ បុគ្គលមានឥទ្ធិពលក្នុង សហគមន៍ ។

## ខ. គោលបំណងនៃឥរិយាបថ

1. យើងចង់ឲ្យប្រជាជនកម្ពុជាទាំងអស់(បុគ្គល និងគ្រួសារ) ជាពិសេសមនុស្សចាស់ និងស្ត្រីដែលជាក្រុមមានហានិភ័យខ្ពស់ក្នុងការឆ្លងជំងឺកូវីដ-១៩ ចូលរួមដោយការទទួលខុសត្រូវ ក្នុងការអនុវត្តវិធានការ "៣ការពារ និង៣កុំ" ដើម្បីការពារខ្លួនគាត់ គ្រួសារគាត់ និងសហគមន៍របស់គាត់ពីជំងឺកូវីដ-១៩ ។
2. យើងចង់ឲ្យស្ថាប័នពាក់ព័ន្ធជាពិសេសស្ថាប័នឯកជន ចូលរួមក្នុងការទទួលខុសត្រូវអនុវត្តន៍វិធានការ NPIs (សេវាកម្មមានសុវត្ថិភាព ទីកន្លែងធ្វើការមានសុវត្ថិភាព) ដូច្នេះពួកគាត់នឹងអាចការពារខ្លួនគាត់ សេវាកម្មរបស់គាត់ឲ្យដំណើរការប្រកបដោយសុវត្ថិភាព ចៀសវាងការចម្លងជំងឺកូវីដ-១៩ ក្នុងទីតាំងរបស់គាត់ ។
3. យើងចង់ឲ្យអាជ្ញាធរមូលដ្ឋានក្នុងសហគមន៍ បង្កើនការទទួលខុសត្រូវក្នុងការជំរុញការចូលរួមរបស់សហគន៍ក្នុងការតាមដានការអនុវត្តវិធានការសុខាភិបាល និងអន្តរាគមន៍ផ្សេងៗនៅក្នុងតំបន់ ដូច្នេះពួកគាត់នឹងអាចទប់ស្កាត់ការរីករាលដាលក្នុងការឆ្លងជំងឺកូវីដ-១៩ ក្នុងសហគមន៍ដោយប្រសិទ្ធភាព ។

## គ. ឧបសគ្គរាំងស្ទះក្នុងការផ្លាស់ប្តូរឥរិយាបថ

ក្រសួងសុខាភិបាល អាជ្ញាធរមូលដ្ឋាន អង្គការជាតិ និងអន្តរជាតិ បានខិតខំប្រឹងប្រែងធ្វើការផ្សព្វផ្សាយ និងអនុវត្តន៍សកម្មភាពអប់រំផ្សព្វផ្សាយតាមរូបភាពផ្សេងៗគ្នាជាច្រើនមកហើយកន្លងមក ដើម្បីទប់ស្កាត់ការរីករាលដាលនៃការឆ្លងជំងឺកូវីដ-១៩ ប៉ុន្តែនៅតែជួបនូវបញ្ហារាំងស្ទះមួយចំនួន ដែលជាឧបសគ្គក្នុងការផ្លាស់ប្តូរផ្នត់គំនិត និងឥរិយាបថរបស់ក្រុមគោលដៅ ។ ខាងក្រោមនេះ គឺជាឧបសគ្គរាំងស្ទះមួយចំនួនរបស់ក្រុមគោលដៅ៖

| ក្រុមគោលដៅ | ឧបសគ្គរាំងស្ទះក្នុងការផ្លាស់ប្តូរឥរិយាបថ |
|---|---|
| **ក្រុមគោលដៅទី១៖** ប្រជាជនកម្ពុជាទាំងអស់ (បុគ្គល និងគ្រួសារ) ជាពិសេស មនុស្សចាស់ និងស្រ្តី | **ចំណេះដឹង៖** *Source: UNICEC-RCCE KAP Survey, May 2020- ការសិក្សាជាមួយប្រធានមន្ទីរសុខាភិបាលនៃរដ្ឋបាលរាជធានី-ខេត្តទាំង២៥*<br>• ប្រជាជនដឹងច្រើនអំពីឥរិយាបថការពារពីជំងឺកូវីដ-១៩ តាមរយៈអជ្ញាធរមូលដ្ឋាន ដូចជាមេភូមិ និងប្រព័ន្ធផ្សព្វផ្សាយនានា ប៉ុន្តែពួកគាត់ដឹងតិចអំពីព័ត៌មានទាក់ទងនឹងជំងឺនេះ ។<br>• សារដែលត្រូវបានពួកគាត់ចងចាំជាទូទៅបំផុត គឺការលាងដៃឲ្យបានទៀងទាត់(៨៨%) ប្រជាជនមួយចំនួនតូច(១០%) មិនបានយល់ថា ឥរិយាបថត្រូវបានស្នើឡើងឲ្យអនុវត្តន៍/ធ្វើនៅក្នុងសារនោះទេ ។<br>• ប្រជាជនហាក់ដូចជាមិនមានការប៉ាន់ស្មានពីភាពធ្ងន់ធ្ងរនៃជំងឺនេះទេ។<br>• ប្រជាជនមិនអនុវត្តន៍នូវវិធានការសុខាភិបាលទេ នៅពេលពួកគាត់ទៅលេងផ្ទះអ្នកជិតខាង ពីព្រោះពួកគាត់គិតថា វាមិនមានហានិភ័យចំពោះពួកគាត់ទេ ។<br>• ការយល់ច្រឡំដូចជា ថាមានហានិភ័យទាបក្នុងការចម្លង ការយល់ឃើញមិនត្រឹមត្រូវ និងការធ្វេសប្រហែសក្នុងការអនុវត្តវិធានការការពារ ។<br>• ការសុខចិត្តទទួលប្រឈមនឹងហានិភ័យ ។<br>• ភាពនឿយណាយជាមួយ និងការផ្ទុះរាតត្បាត ។<br>• មិនសូវចាប់អារម្មណ៍ (complacency) ។<br>**ការប្រព្រឹត្ត៖** Soruce: The Results of Monitoring COVID-19 Non-Pharmaceutical Public Health Interventions(NPI), May 2021.<br>• ១៦,៣៨% នៃប្រជាជន មានការលំបាកក្នុងការទទួលយកអនុសាសន៍នៅលើការរក្សាចម្ងាយរាងកាយ ១,៥ ម៉ែត្រពីប្រជាជនផ្សេងទៀត ។<br>• ប្រជាជនខ្វះអនាម័យនៅផ្ទះ និងកន្លែងធ្វើការ ។ |

| | |
|---|---|
| | **បរិយាកាសជុំវិញ៖**<br>• ទម្លាប់សង្គម និងបរិស្ថានជុំវិញ មិនទាន់បានបង្កើតឡើងដើម្បីបង្កលក្ខណៈងាយស្រួលដល់ប្រជាជនក្នុងការអនុវត្តវិធានការសុខាភិបាល ។<br>• ហេតុផលផ្សេងទៀត ដែលបានលើកឡើងដោយប្រជាជនគឺ៖<br>  ○ សាប៊ូ ឬអាល់កុលលាងដៃ មិនមានតម្លៃសមរម្យទេ<br>  ○ ទោះបីខ្ញុំរក្សាគម្លាត តែអ្នកផ្សេងក៏មិនធ្វើដូចខ្ញុំដែរ<br>  ○ មនុស្សដែលខ្ញុំរស់នៅជាមួយមានសុខភាពល្អ ដូច្នេះមិនចាំបាច់រក្សាគម្លាតទេ<br>  ○ អាហារ និងការផ្គត់ផ្គង់ គឺចាំបាច់ (ដូច្នេះចាំបាច់ត្រូវចេញទៅក្រៅ)<br>  ○ អ្នកផ្សេងទៀតដែលខ្ញុំរស់នៅជាមួយមិនអនុវត្តន៍វិធានការសុខាភិបាលទេ ដូច្នេះហេតុអ្វីខ្ញុំត្រូវធ្វើ? *-source: UNICEC-RCCE KAP Survey, May 2020*។<br>• ជឿជាក់ខ្លាំងបន្ទាប់ពីចាក់វ៉ាក់សាំងហើយ (Vaccine optimism) ។<br>• មិនទាន់មានការតាមដានការអនុវត្តឲ្យបានម៉ត់ចត់ (ការអនុវត្តវិធានរដ្ឋបាលជាដើម)។<br>• ការចូលរួមរបស់ស្ថាប័នពាក់ព័ន្ធសេវាឯកជននៅមិនទាន់ពេញលេញ។ |
| **ក្រុមគោលដៅទី២៖**<br>ស្ថាប័នពាក់ព័ន្ធជាពិសេសស្ថាប័នឯកជន | • ការចូលរួមរបស់ស្ថាប័នពាក់ព័ន្ធសេវាឯកជននៅមិនទាន់ពេញលេញ ដោយសារមិនទាន់យល់ដឹងអំពីតួនាទី និងការទទួលខុសត្រូវរបស់ខ្លួនក្នុងការការពារការចម្លងវីរុសកូវីដ-១៩។<br>• ពឹងផ្អែកទៅលើផ្នែកសុខាភិបាលក្នុងការអប់រំ ផ្សព្វផ្សាយ និងចុះតាមដានការអនុវត្ត NPIs ដោយខ្វះភាពម្ចាស់ការ និងការទទួលខុសត្រូវអំពីសេវាឯកជនផ្ទាល់<br>• មិនទាន់យល់ដឹងអំពីហានិភ័យ។ យល់ច្រលំថា មានហានិភ័យទាបក្នុងការចម្លង ការយល់ឃើញមិនត្រឹមត្រូវ និងការធ្វេសប្រហែសក្នុងការអនុវត្តវិធានការការពារ។ |
| **ក្រុមគោលដៅទី៣៖**<br>អជ្ញាធរមូលដ្ឋានក្នុងសហគមន៍ | • មិនទាន់យល់ដឹងអំពីហានិភ័យ។ យល់ច្រលំថា មានហានិភ័យទាបក្នុងការចម្លង ការយល់ឃើញមិនត្រឹមត្រូវ និងការធ្វេសប្រហែសក្នុងការអនុវត្តវិធានការការពារមិនទាន់យល់ច្បាស់ពីតួនាទីរបស់ខ្លួន និងខ្វះសមត្ថភាព ធនធានក្នុងការអនុវត្ត។ |

## ឃ. កត្តាជំរុញលើកទឹកចិត្តក្នុងការផ្លាស់ប្តូរឥរិយាបថ

បើទោះបីជាមានឧបសគ្គរាំងស្ទះក្នុងការផ្លាស់ប្តូរឥរិយាបថក៏ដោយ ក៏មានក្រុមគោលដៅមួយចំនួនបានផ្លាស់ប្តូរឥរិយាបថក្នុងការអនុវត្តនូវវិធានការសុខាភិបាលផងដែរ។ ខាងក្រោមនេះគឺជាកត្តាជំរុញលើកទឹកចិត្តមួយចំនួនរបស់ក្រុមគោលដៅ៖

| ក្រុមគោលដៅ | កត្តាជំរុញលើកទឹកចិត្តក្នុងការផ្លាស់ប្តូរឥរិយាបថ |
|---|---|
| **ក្រុមគោលដៅទី១៖** ប្រជាជនកម្ពុជាទាំងអស់ (បុគ្គល និង គ្រួសារ) ជាពិសេសមនុស្សចាស់ និងស្ត្រី | **ចំណេះដឹង៖**<br>• ប្រជាជនបានទទួលយល់ដឹងសារណែនាំពីក្រសួងសុខាភិបាល និងជាពិសេសពី អាជ្ញាធរមូលដ្ឋានយ៉ាងច្បាស់លាស់ និងគ្រប់ជ្រុងជ្រោយអំពីវិធានការការពារ ។ *-source: UNICEC-RCCE KAP Survey, May 2020*<br>**ការប្រព្រឹត្ត៖**<br>• ប្រជាជនមួយចំនួនមានទម្លាប់ល្អក្នុងការធ្វើអនាម័យតាំងពីមុនជំងឺកូវីដ-១៩ នេះមកដល់ប្រទេសកម្ពុជា ដូច្នេះពួកគាត់ងាយស្រួលនឹងអនុវត្តន៍វិធានការសុខាភិបាល យ៉ាងឆាប់រហ័ស ។ *-source: UNICEC-RCCE KAP Survey, May 2020*<br>**បរិយាកាសជុំវិញ៖**<br>• មិត្តភក្តិ ឬសមាជិកគ្រួសារ សហគមន៍របស់ពួកគាត់ បានអនុវត្តន៍វិធានការសុខាភិបាល ដូច្នេះពួកគាត់ត្រូវតែអនុវត្តន៍តាមដែរ ដើម្បីចូលរួមទប់ស្កាត់ការឆ្លងរីករាលដាលនៃជំងឺនេះ ។ *-source: UNICEC-RCCE KAP Survey, May 2020* |
| **ក្រុមគោលដៅទី២៖** ស្ថាប័នពាក់ព័ន្ធជាពិសេសស្ថាប័នឯកជន | • ស្ថាប័នពាក់ព័ន្ធ សេវាឯកជន ត្រូវការដំណើរការសេវារបស់ខ្លួនដើម្បីដំណើរការសេដ្ឋកិច្ច និងសង្គម ដូច្នេះការចូលរួមចំណែកទទួលខុសត្រូវអនុវត្តន៍ NPIs ដោយមានការណែនាំ និងការទទួលខុសត្រូវមានប្រយោជន៍សម្រាប់សេវាកម្មរបស់គាត់។ |
| **ក្រុមគោលដៅទី៣៖** អជ្ញាធរមូលដ្ឋានក្នុងសហគមន៍ | អាជ្ញាធរ ត្រូវការធានាសុវត្ថិភាព និងដំណើរការសេដ្ឋកិច្ចសម្រាប់គ្រួសារ និងសហគមន៍របស់គាត់ការធានាបាននូវការអនុវត្តវិធានការសុខាភិបាលក្នុង មូលដ្ឋានរបស់គាត់ធ្វើឲ្យប្រជាជនមានជំនឿចិត្តលើអាជ្ញាធរ។ |

## ង. សារគន្លឹះសម្រាប់យុទ្ធនាការ

យុទ្ធនាការនេះគឺជាការទំនាក់ទំនងដែលប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយទូលំទូលាយ សារដែលមានលក្ខណៈផ្តោត និងសកម្មភាពទំនាក់ទំនងជាច្រើនដើម្បីសម្រេចបាននូវលទ្ធផលមួយសម្រាប់បុគ្គល និងសហគមន៍ជាច្រើនក្នុងពេលវេលាមួយជាក់លាក់។ វាជាយុទ្ធនាការលើកកម្ពស់ការយល់ដឹង បរិបទសង្គម និងកត្តាបរិស្ថានរបស់បុគ្គល និងសង្គមដើម្បីឈានទៅសម្រេចនូវការផ្លាស់ប្តូរឥរិយាបថ និងចុងបញ្ចប់គឺទទួលបានសកម្មភាពការប្រព្រឹត្តដែលយើងចង់បាន។ សារអប់រំសម្រាប់យុទ្ធនាការ ត្រូវផ្តោតលើវិធីសាស្រ្តកាត់ផ្តាច់ខ្សែចម្លងជំងឺកូវីដ-១៩ និងធ្វើការទំនាក់ទំនងជាមួយប្រជាជនអំពីស្ថានភាពរបស់ជំងឺដើម្បីឱ្យប្រជាជនដឹងអំពីភាពធ្ងន់ធ្ងរ និងទំហំនៃបញ្ហាពិតប្រាកដ។ សារគន្លឹះនឹងផលិតដោយក្រសួងសុខាភិបាល ដើម្បធានាសង្គតិភាព ។

| សារគន្លឹះ | | |
|---|---|---|
| ១. យើងកំពុងស្ថិតនៅក្នុងស្ថានភាពគ្រោះថ្នាក់បំផុតជាមួយគ្នា<br>• ការចម្លងកំពុងបន្តកើនឡើងវីរុសបំប្លែងខ្លួនថ្មីបានមកដល់<br>• មិនមានការបិទខ្ទប់ តែមិនមានន័យថា យើងបានបញ្ចប់ការរាតត្បាតនោះទេ<br>• ការរស់នៅតាមបែបគន្លងថ្មីសម្រាប់ដំណើរការសេដ្ឋកិច្ចសង្គមដែលយើងទាំងអស់គ្នាត្រូវការ<br>• ត្រូវរស់នៅតាមបែបគន្លងថ្មីទាំងអស់គ្នាដើម្បីសង្គ្រោះជីវិត | ២. លើកទឹកចិត្តការធ្វើតេស្តកូវីដ-១៩ ការចាក់វ៉ាក់សាំង ការស្វែងរកការព្យាបាល និងការផ្លាស់ប្តូរឥរិយាបទ | ៣. ការទំនាក់ទំនងពិសេសសម្រាប់រដូវបុណ្យទាន អាពាហ៍ពិពាហ៍ និងពិធីផ្សេងៗ |








# ៤. យុទ្ធសាស្ត្រក្នុងការអនុវត្តយុទ្ធនាការ

គោលបំណងសំខាន់សម្រាប់យុទ្ធនាការនេះគឺ ដើម្បីលើកកម្ពស់គុណតម្លៃសង្គម និងសាមគ្គីភាពសង្គមក្នុងការរួមចំណែកទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩។ យុទ្ធនាការនេះមានរយៈពេល៥ខែ ចាប់ពីខែសីហា ដល់ខែធ្នូ ឆ្នាំ២០២១ ដែលមានលក្ខណៈល្អិតល្អន់ និងសម្រុក(Intensive) ដោយប្រើប្រាស់សារគន្លឹះងាយយល់ សាមញ្ញ ដែលបានរៀបរាប់ខាងលើ និងសម្ភារសម្រាប់ផ្លាស់ប្តូរឥរិយាបថតាមរយៈការប្រាស្រ័យទាក់ទង ដែលអាចទៅដល់គ្រប់ប្រជាជនកម្ពុជាទាំងអស់។ យុទ្ធនាការទំនាក់ទំនងនេះ ត្រូវតម្រង់ទិសទៅទីកន្លែងដែលមានការឆ្លងច្រើន និងទីតាំងដែលមានកន្លែងហានិភ័យខ្ពស់ ។

យុទ្ធសាស្ត្រពីរដែលប្រើសម្រាប់យុទ្ធនាការគឺ៖ ទំនាក់ទំនងអន្តរបុគ្គល និងយុទ្ធនាការតាមរយៈប្រព័ន្ធផ្សព្វផ្សាយ ដែលត្រូវធ្វើទន្ទឹមគ្នា។ ការអប់រំផ្សព្វផ្សាយនឹងត្រូវធ្វើឡើងតាមគ្រប់ប្រព័ន្ធ ដូចជាបណ្តាញសង្គម ទំនាក់ទំនងបុគ្គលផ្ទាល់ និងប្រព័ន្ធផ្សព្វផ្សាយនានា តាមរយៈទូរស័ព្ទ។ល។ និងតម្រូវឲ្យធ្វើឡើងព្រមគ្នាគ្រប់ស្ថាប័ន សេវាឯកជន និងថ្នាក់ក្រោមជាតិ ។ ខាងក្រោមនេះ គឺជាការពិពណ៌នានូវខ្លឹមសារកម្រិតខ្ពស់នៃយុទ្ធសាស្ត្រសំខាន់ៗទាំងពីរ របស់យុទ្ធនាការដែលត្រូវបានគេរំពឹងថានឹងដំណើរការសម្រាប់រយៈពេល ៥ខែ៖

## ក. យុទ្ធសាស្ត្រទី១៖ ទំនាក់ទំនងអន្តរបុគ្គល





អនុគណៈកម្មការអប់រំ បណ្តុះបណ្តាល និងទំនាក់ទំនងសាធារណៈនៃគណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩បានផលិតសម្ភារ/សារអប់រំផ្លាស់ប្តូរឥរិយាបថជាច្រើនកន្លងមក សម្រាប់អប់រំផ្សព្វផ្សាយដល់ប្រជាជនកម្ពុជាទាំងមូលទាក់ទងនឹងចំណេះដឹងក្នុងការការពារ និងជំហានដែលប្រជាជនត្រូវអនុវត្តន៍ក្នុងការថែរក្សាការពារសុខភាពរបស់ពួកគាត់ដើម្បីកាត់បន្ថយហានិភ័យនៃការឆ្លងទៅក្រុមងាយរងគ្រោះក្នុងសហគមន៍។

ដូច្នេះដើម្បីឆ្លើយតបទៅនឹងគោលបំណងរបស់យុទ្ធនាការ យុទ្ធសាស្ត្រទី១នេះ តម្រូវឲ្យមានការលើកទឹកចិត្តដល់ស្ថាប័នរាជរដ្ឋាភិបាល អាជ្ញាធរ សង្គមស៊ីវិលបណ្តុះបណ្តាលធនធាន (អ្នកផ្តល់សេវា មិត្តអប់រំមិត្ត

អ្នកស្ម័គ្រចិត្ត) ឲ្យចូលរួមផ្សព្វផ្សាយសម្ភារ/សារ តាមរយៈការផ្តល់សេវា ការប្រើប្រាស់សម្ភារអប់រំ ការជួបជុំក្នុងសហគមន៍ និងការផ្សព្វផ្សាយផ្ទាល់ បង្កើតជាជនបង្គោលសហគមន៍សម្រាប់ផ្សព្វផ្សាយ។ សារសំខាន់ៗមានការពាក់ម៉ាស់ អនាម័យដៃ ការធ្វើតេស្ត ការសម្គាល់រោគសញ្ញាសង្ស័យ និងការចាក់វ៉ាក់សាំងជាដើម។

## ខ. យុទ្ធសាស្ត្រទី២៖ ការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ

យោងតាមរបាយការណ៍សិក្សាស្រាវជ្រាវរបស់អង្គការ Save the Children ក្នុងខែឧសភា ឆ្នាំ២០២០ បានបង្ហាញឲ្យឃើញថា គ្រួសារកម្ពុជាភាគច្រើនមានទូរស័ព្ទដៃទំនើប(៩៩%) (១០០% នៅទីក្រុងនិង ៩៨,៥% នៅជនបទ)។ ពួកគេទាំងអស់ ប្រើអ៊ិនធឺណែតតាមរយៈទូរស័ព្ទដៃចល័ត។ ស្រដៀងគ្នានេះដែរ ភាគច្រើននៃគ្រួសារកម្ពុជាមានគណនី Facebook (៩៧%) ស្រដៀងគ្នារវាងទីក្រុង និងជនបទ(៩៨% ទល់នឹង ៩៥%)។ ហើយប្រហែល ១ ក្នុងចំណោម ៤ គ្រួសារប្រើ Telegram (២៣%) នៅទីប្រជុំជនគឺច្រើនជាងជនបទ (២៨% ទល់នឹង ២០%) ។

ដូច្នេះដើម្បីផ្សព្វផ្សាយសារដល់សាធារណៈជនបានចំនួនច្រើន ក្នុងពេលតែមួយដោយឆាប់រហ័ស វាមានសារៈសំខាន់ណាស់ក្នុងការរើសបណ្តាញដែលមានប្រសិទ្ធភាពក្នុងការបញ្ជូនសារទៅដល់ក្រុមគោលដៅឲ្យបានឆាប់ ។

- សម្ភារបោះពុម្ព៖ ផ្ទាំងប៉ាណូ រូបភាពផ្ទាំងធំ បដា សន្លឹកបត់ កាសែត
- វិទ្យុ
- ទូរទស្សន៍គ្រប់បណ្តាញទាំងអស់
- បណ្តាញសង្គម
- សម្លេងសារទូរស័ព្ទ (call tune)
- ឧបករណ៍បំពងសម្លេង
- ការផ្សព្វផ្សាយ (public announcement) តាមទីតាំងផ្សេងៗ ដូចជា ផ្សារទំនើប ទីតាំងអាជីវកម្ម រោងចក្រ ...ជាដើម។




នៅពេលអ្នក៖







# ៥. សកម្មភាពយុទ្ធនាការ

## ក. សកម្មភាពយុទ្ធនាការថ្នាក់ជាតិ

យុទ្ធនាការអប់រំផ្សព្វផ្សាយអំពីជំងឺកូវីដ-១៩បាននឹងកំពុងប្រព្រឹត្តទៅតាំងពីដើមឆ្នាំ២០២០ មកម្លេះហើយក៏កំពុងបន្តសកម្មភាពក្នុងលក្ខណៈជាការងារប្រចាំរបស់មន្ត្រីសុខាភិបាល និងអាជ្ញាធរមូលដ្ឋាន ប៉ុន្តែមិនទាន់មានទ្រង់ទ្រាយធំ និងមានលក្ខណៈព្រមគ្នានៅឡើយ។ ការប្រកាសយុទ្ធនាការថ្នាក់ជាតិពេលនេះជាសកម្មភាពដ៏ចម្បងក្នុងការពញ្ញាក់ស្មារតីក្រុមគោលដៅទាំងអស់ដើម្បីជាការក្រើនរំលឹកអំពីស្ថានភាពដ៏លំបាកដែលយើងទាំងអស់គ្នាកំពុងតែឆ្លងកាត់ និងការទាមទារឲ្យមានការភ្ញាក់រលឹក និងការទទួលខុសត្រូវរួមពីបុគ្គលគ្រប់រូប គ្រួសារ និងសហគមន៍ព្រោះថា បុគ្គលគ្រប់រូបមានតួនាទីសំខាន់ក្នុងការទប់ស្កាត់ការចម្លងវីរុសកូវីដ-១៩ដោយការពារមិនឲ្យមានការចម្លងវីរុសកូវីដ-១៩ ដល់ខ្លួនឯង គ្រួសារ និងសហគមន៍។ សកម្មភាពមួយចំនួនដែលត្រូវធ្វើដើម្បីទាក់ទាញការចាប់អារម្មណ៍ពីសាធារណៈជនលើយុទ្ធនាការ រួមមាន៖

- ប្រកាសយុទ្ធនាការថ្នាក់ជាតិ
- រៀបចំតែងលម្អ ដាក់ភ្លើង “Light up a monument or landmark” ទីតាំងសំខាន់ៗក្នុងរាជធានី-ខេត្ត ទីសាធារណៈ ដាក់តាំងសារ បដា
- ការទូងស្គរនៅតាមវត្តអារាម
- តាំងលម្អដាក់ភ្លើង បដានៅមន្ទីរពេទ្យ ដើម្បីបង្ហាញពីការគោរព គាំទ្រ និងអំណរគុណដល់គ្រូពេទ្យ
- ចែករំលែករូបភាពទាំងអស់នេះតាមបណ្តាញសង្គម Using hash tags
- សន្និសិទ្ធសារព័ត៌មានថ្នាក់ជាតិ រៀងរាល់ខែ
- គ្រប់ស្ថាប័នថ្នាក់ជាតិ ក្រសួងពាក់ព័ន្ធនានាត្រូវរៀបចំសកម្មភាពផ្សព្វផ្សាយផ្សេងៗ តាមអនឡាញ (online) ឬការជួបជុំផ្ទាល់តាមដែលអាចធ្វើបាន។

## ខ. សកម្មភាពយុទ្ធនាការនៅរាជធានី-ខេត្ត

ការប្រកាសបើកយុទ្ធនាការនៅថ្នាក់ខេត្តគួរធ្វើឡើងដោយអភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត ពញ្ញាក់ស្មារតីក្រុមគោលដៅទាំងអស់ អំពីស្ថានភាពដ៏លំបាកដែលយើងទាំងអស់គ្នាកំពុងតែឆ្លងកាត់ និងបង្ហាញអំពីប្រធានបទថ្មីរបស់យុទ្ធនាការដែលទាមទារឲ្យមានការចូលរួមទទួលខុសត្រូវពីគ្រប់ភាគីពាក់ព័ន្ធ និងបុគ្គលទាំងអស់។ លើសពីនេះការប្រកាសយុទ្ធនាការគួរមានសកម្មភាពសំខាន់ៗដូចជា៖

- រៀបចំតែងលម្អ ដាក់ភ្លើង “Light up a monument or landmark” ទីតាំងសំខាន់ៗក្នុងរាជានី-ខេត្ត ទីសាធារណៈ ដាក់តាំងសារ បដា របស់យុទ្ធនាការ
- ការទូងស្គរនៅតាមវត្តអារាមក្នុងខេត្ត ស្រុក ឃុំ
- តាំងលម្អដាក់ភ្លើង បដានៅមន្ទីរពេទ្យ ដើម្បីបង្ហាញពីការគោរព គាំទ្រ និងអំណរគុណដល់គ្រូពេទ្យ
- ចែករំលែករូបភាពទាំងអស់នេះតាមបណ្តាញសង្គម Using hash tags. ដោយប្រើសារ **"រួមគ្នាទទួលខុសត្រូវទប់ស្កាត់ការចម្លងវីរុសកូវីដ-១៩"** ។
- គ្រប់ស្ថាប័ន រាជធានី-ខេត្តរៀបចំចំសកម្មភាពផ្សេងៗ តាមអនឡាញ(online) ឬការជួបជុំផ្ទាល់តាមដែលអាចធ្វើបាន ។
- រៀបចំការបណ្តុះបណ្តាលដល់ជនបង្គោល អាជ្ញាធរ មន្ត្រីសុខាភិបាល ។ ការបណ្តុះបណ្តាលដល់អាជ្ញាធរ ស្រុក ឃុំ ភូមិ ក្រុមទ្រទ្រង់សុខភាពភូមិ និងបណ្តាញសហគមន៍អំពីយុទ្ធនាការអប់រំផ្សព្វផ្សាយដោយបែងចែកតួនាទី និងភារកិច្ចច្បាស់លាស់ដល់អាជ្ញាធរ និងផ្តល់នូវធនធានសមស្របសម្រាប់ការអនុវត្តសកម្មភាព ។
- សកម្មភាពអប់រំផ្សព្វផ្សាយតាមទីតាំងនានា និងសេវាឯកជន (វត្តអារាម រោងចក្រ ទីផ្សារ ភោជនីយដ្ឋាន ទីតាំងចំណតរថយន្ត ពីធីផ្សេងៗ) ដោយសហការជាមួយសេវាឯកជន។ រាជធានី-ខេត្តផ្សព្វផ្សាយដល់សេវាឯកជន និងស្ថាប័នពាក់ព័ន្ធក្នុងរាជធានី-ខេត្តទាំងអស់អំពីយុទ្ធនាការ និងអំពាវនាវដល់ពួកគាត់ចូលរួមទទួលខុសត្រូវអនុវត្តន៍ឲ្យមានប្រសិទ្ធភាព។ លើកទឹកចិត្តដល់សមាគម អាជីវកម្មផ្សេងៗចូលរួមតាមដានការអនុវត្តវិធានការនៅតាមសេវាកម្ម និងអាជីវកម្ម នានា ។
- រៀបចំឲ្យមានការផ្តល់សារពីគ្រូពេទ្យ អ្នកដឹកនាំសាសនា អ្នកមានឥទ្ធិពលក្នុងសហគមន៍ចូលរួមផ្សព្វផ្សាយអំពីការចូលរួមគ្រប់គ្នាការពារការចម្លងកូវីដ-១៩តាមបណ្តាញសង្គម ផ្តល់ការសម្ភាសតាមវិទ្យុ ទូរទស្សន៍ជាដើម ។ លើកទឹកចិត្តដល់គ្រូពេទ្យ អ្នកដឹកនាំសាសនា អ្នកមានឥទ្ធិពលក្នុងសហគមន៍ ប្រើរូបថតរបស់ពួកគាត់ព្រមទាំងសារ និងឡូហ្គោរបស់យុទ្ធនាការដើម្បីផ្សព្វផ្សាយតាមបណ្តាញសង្គមរបស់គាត់ ឬបណ្តាញសង្គមរបស់ស្ថាប័ន។
- ផ្សព្វផ្សាយតាមឧបករណ៍បំពងសម្លេង នៅតាមភូមិឃុំ ជាពិសេស ទីប្រជុំជន ទីតាំងមានហានិភ័យខ្ពស់។
- ផ្សព្វផ្សាយស្ប៊ែតអប់រំនៅគ្រប់ទីតាំងសុខាភិបាល ទីសាធារណៈនានា។
- បិទតាំងសម្ភារអប់រំសុខភាពនៅគ្រប់ភូមិទាំងអស់។

- រៀបចំក្រុមទ្រទ្រង់សុខភាពភូមិ គកនក ចុះចែកចាយផ្សព្វផ្សាយសារអប់រំក្នុងភូមិ និងចូលរួមជំរុញការអនុវត្តវិធានការសុខាភិបាល។
- ចុះតាមដាន និងគាំទ្រយុទ្ធនាការដោយក្រុមការងារថ្នាក់រាជធានី-ខេត្ត ស្រុក ក្រុង ខ័ណ្ឌ ឃុំសង្កាត់ ភូមិ ដើម្បីតាមដានការអនុវត្តវិធានការសុខាភិបាលនៅក្នុងមូលដ្ឋានភូមិឃុំ និងទីតាំងសេវាកម្មនានាក្នុងភូមិឃុំ។ កំណត់ទីតាំងដែលមានហានិភ័យក្នុងមូលដ្ឋាន និងរៀបចំក្រុមការងារដើម្បីចុះពិនិត្យតាមដាន និងរកវិធានការដោះស្រាយសមស្របទាន់ពេលវេលាប្រសិនបើមានការមិនគោរពតាមវិធានការសុខាភិបាល ។

## គ. សកម្មភាពយុទ្ធនាការពីស្ថាប័នពាក់ព័ន្ធក្រសួងប្រៃសណីយនិងទូរគមនាគមន៍ ៖ បណ្តាញសង្គម និងទូរស័ព្ទ

- ផ្សព្វផ្សាយសារតាមបណ្តាញសង្គម Use hash tags ដោយប្រើសារ "រួមគ្នាទទួលខុសត្រូវទប់ស្កាត់ការចម្លងវីរុស កូវីដ-១៩"។
- អញ្ជើញតារាសិល្បៈ គ្រូពេទ្យ អ្នកមានឥទ្ធិពល( influencers) ក្នុងតំបន់ថតរូបរបស់គាត់ ជាមួយចំណងជើង(with caption) ដោយប្រើសារ "រួមគ្នាទទួលខុសត្រូវទប់ស្កាត់ការចម្លងវីរុសកូវីដ-១៩" ។
- អញ្ជើញតារាសិល្បៈចូលរួមផ្តល់បទសម្ភាស អំពីសារៈសំខាន់នៃការចូលរួមទទួលខុសត្រូវរបស់បុគ្គលគ្រប់រូបក្នុងការទប់ស្កាត់ការចម្លងវីរុសកូវីដ-១៩។

## ឃ. សកម្មភាពយុទ្ធនាការពីស្ថាប័នពាក់ព័ន្ធ ក្រសួងព័ត៌មាន៖ ប្រព័ន្ធផ្សព្វផ្សាយ

- ការចូលរួមរបស់ប្រព័ន្ធផ្សព្វផ្សាយ ក្នុងការផ្សព្វផ្សាយនូវព័ត៌មានដែលត្រឹមត្រូវ សារអប់រំផ្សេងៗ។
- ជំរុញប្រព័ន្ធផ្សព្វផ្សាយចូលរួមផលិតកម្មវិធីផ្សេងៗដូចជា កម្មវិធីទូរទស្សន៍ វិទ្យុ ដែលលើកកម្ពស់ការរស់នៅតាមបែបគន្លងថ្មី។
- រៀបចំឲ្យមានការផ្តល់សារពីគ្រូពេទ្យ អ្នកដឹកនាំសាសនា អ្នកមានឥទ្ធិពលក្នុងសហគមន៍ចូលរួមផ្សព្វផ្សាយអំពីការចូលរួមគ្រប់គ្នាការពារការចម្លងកូវីដ-១៩ តាមបណ្តាញសង្គម ផ្តល់ការសម្ភាសតាមវិទ្យុ ទូរទស្សន៍ជាដើម។
- សហការជាមួយស្ថានីយទូរទស្សន៍ វិទ្យុក្នុងតំបន់ដើម្បីផលិតកម្មវិធីផ្សេងៗ។

## ង. សកម្មភាពយុទ្ធនាការពី ស្ថាប័នពាក់ព័ន្ធ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

- ការចូលរួមរបស់អ្នកសិល្បៈ ដូចជាការគូរគំនូរ សម្តែង...។

- ផលិតចម្រៀង (Create songs or jingles) អំពីតម្រូវការការអនុវត្តវិធានការការពារដើម្បីជំរុញការរស់នៅតាមបែបគន្លងថ្មី។
  ជំរុញការតែងនិពន្ធកំណាព្យ អត្ថបទជំរុញការរស់នៅតាមបែបគន្លងថ្មី។

### ច. សកម្មភាពយុទ្ធនាការពីស្ថាប័នពាក់ព័ន្ធ៖ ស្ថាប័នអប់រំ

- រៀបចំសកម្មភាពអនទ្បាយ ជាមួយសិស្ស និស្សិត ជំរុញការរស់នៅតាមបែបគន្លងថ្មី។
- ជំរុញឲ្យមានការបញ្ចូល ការរស់នៅតាមបែបគន្លងថ្មីក្នុងសៀវភៅសិក្សា។

### ឆ. រៀបចំការបិទតាំង និងវត្ថុអនុស្សាវរីយ៍

- ផលិត និងដាក់តាំងបដា រូបភាពផ្ទាំងធំ ដាក់បង្ហាញសារតាម LED។

ផលិតចែកចាយសម្ភារអនុស្សាវរីយ៍សម្រាប់យុទ្ធនាការដូចជា អាវយឺត មួក កាបូប កែវ ស្ទិកឃ័រសម្រាប់បិទរថយន្ត និងសម្ភារផ្សេងៗទៀត ។

## ៦. សម្ភារសម្រាប់យុទ្ធនាការ

យុទ្ធនាការនេះ ត្រូវការសម្ភារមួយចំនួនដើម្បីទាក់ទាញចំណាប់អារម្មណ៍របស់សាធារណៈជនអំពីគោលរឿងនៃយុទ្ធនាការ។ សម្ភាររួមមានសារអប់រំដែលបានផលិតកន្លងមក និងសម្ភារបន្ថែមមួយចំនួនដូចជា ៖ អាវយឺត, មួក (T-shirt, Cap)ពាក្យស្លោក៖ រួមគ្នាទទួលខុសត្រូវទប់ស្កាត់ការចម្លងវីរុសកូវីដ-១៩ បដា និងសារសម្លេងង ស្ពតវិទ្យុ និងស្ពតទូរទស្សន៍ ដែលនឹងផលិតជាបន្តបន្ទាប់ទៀត។ **(សូមពិនិត្យមើលឧបសម្ព័ន្ធទី១ ៖ សម្ភារដែលនឹងផលិតបន្ថែម)**

## ៧. ការត្រួតពិនិត្យ តាមដាន និងវាយតម្លៃ

តាមរយៈការអនុវត្តយុទ្ធសាស្ត្រខាងលើ ក្រុមការងារនឹងបញ្ចូលយុទ្ធសាស្ត្រត្រួតពិនិត្យ តាមដាន និងវាយតម្លៃសាមញ្ញមួដើម្បីកំណត់ពីប្រសិទ្ធភាព និងគុណតម្លៃរបស់យុទ្ធនាការ តាមរយៈការវាស់វែងនូវសូចនាករដូចខាងក្រោម៖

- % នៃតំបន់ដែលយុទ្ធនាការគ្របដណ្តប់ (គ្រប់ប្រជាជន)
- % នៃការកើនឡើងផ្នែកចំណេះដឹង ការយល់ឃើញរបស់ប្រជាជនចំពោះហានិភ័យនៃជំងឺកូវីដ-១៩
  - ការយល់ឃើញអំពីហានិភ័យ

    - ការព្រមទទួលយកហានិភ័យថយចុះ
- % នៃការផ្លាស់ប្តូរឥរិយាបថ
    - ពាក់ម៉ាស់ លាងដៃ និងរក្សាគម្លាត
- % នៃសេវាកម្ម ទីកន្លែងធ្វើការ មានសុវត្ថិភាព
- % នៃការចម្លងថយចុះ

# ៨. ផែនការសកម្មភាពក្នុងការអនុវត្តយុទ្ធនាការ

| ល.រ | សកម្មភាព | ពេលវេលាផ្សព្វផ្សាយ | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | សីហា | | | | កញ្ញា | | | | តុលា | | | | វិច្ឆិកា | | | | ធ្នូ | | | | |
| | | W1 | W2 | W3 | W4 | W1 | W2 | W3 | W4 | W1 | W2 | W3 | W4 | W1 | W2 | W3 | W4 | W1 | W2 | W3 | W4 | |
| ១ | រៀបចំផែនការយុទ្ធនាការ និងការផ្សព្វផ្សាយផែនការដល់រាជធានី ខេត្ត | x | x | | | | | | | | | | | | | | | | | | | |
| ២ | រៀបចំសម្ភារផ្សព្វផ្សាយ និងការបោះពុម្ព | x | x | X | x | x | x | x | x | x | x | x | x | | | | | | | | | |
| ៣ | រៀបចំ call tune ផ្លាស់ប្តូររាល់ ២សប្តាហ៍ | | x | X | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x |
| ៤ | ប្រកាសយុទ្ធនាការជាតិ | | x | | | | | | | | | | | | | | | | | | | |
| ៥ | ប្រកាសយុទ្ធនាការនៅគ្រប់រាជធានី-ខេត្ត | | x | | | | | | | | | | | | | | | | | | | |
| ៦ | គ្រប់ស្ថាប័ន រាជធានី ខេត្តរៀបចំសកម្មភាពផ្សេងៗ តាមអនឡាយ ឬការជួបជុំផ្ទាល់តាមដែលអាចធ្វើបាន | | x | X | x | x | x | x | x | | | | | | | | | | | | | |
| ៧ | សន្និសិទ្ធសារព័ត៌មាន | | x | | | | x | | | | x | | | | x | | | | x | | | |
| ៨ | រៀបចំតែងលំអរ ដាក់ភ្លើង "Light up a monument or landmark" ទីតាំងសំខាន់ៗក្នុងរាជធានីខេត្ត ទីសាធារណៈ ដាក់តាំងសារ បដា | | | X | x | x | x | x | x | x | x | x | x | x | x | x | x | x | x | | | |
| ៩ | ការទូងស្គនៅតាមវត្តអារាម | | | X | x | x | | | | | | | | | | | | | | | | |
| ១០ | តាំងលំអដាក់ភ្លើង បដានៅមន្ទីរពេទ្យ ដើម្បីបង្ហាញពីការគោរព គាំទ្រ និងអំណរគុណដល់គ្រូពេទ្យ | | | X | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | |

| ល.រ | សកម្មភាព | ពេលវេលាផ្សព្វផ្សាយ | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | សីហា | | | | កញ្ញា | | | | តុលា | | | | វិច្ឆិកា | | | | ធ្នូ | | | |
| | | W1 | W2 | W3 | W4 | W1 | W2 | W3 | W4 | W1 | W2 | W3 | W4 | W1 | W2 | W3 | W4 | W1 | W2 | W3 | W4 |
| ១១ | រៀបចំឲ្យមានការផ្តល់សារពីគ្រូពេទ្យ អ្នកដឹកនាំសាសនា អ្នកមានឥទ្ធិពលក្នុងសហគមន៍ចូលរួមផ្សព្វផ្សាយអំពីការចូលរួមគ្រប់គ្នាការពារការចម្លងកូវីដ-១៩ តាមបណ្តាញសង្គម ផ្តល់ការសម្ភាសតាមវិទ្យុ ទូរទស្សន៍ជាដើម | | X | x | x | x | x | x | x | x | x | x | x | x | x | x | x | | | | |
| ១២ | ចែករំលែករូបភាពទាំងអស់នេះតាមបណ្តាញសង្គម Using hash tags. | | | | | | | | | | | | | | | | | | | | |
| ១៣ | រៀបចំការបណ្តុះបណ្តាលដល់ជនបង្គោល អាជ្ញាធរ មន្ត្រីសុខាភិបាល | | X | x | x | x | x | x | x | x | x | x | x | x | x | x | x | | | | |
| ១៤ | រៀបចំក្រុមទ្រទ្រង់សុខភាពភូមិ គគនក ចុះចែកចាយផ្សព្វផ្សាយសារអប់រំក្នុងភូមិ និងចូលរួមជំរុញការអនុវត្តវិធានសុខាភិបាល | | X | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x |
| ១៥ | បិទតាំសម្ភារតាមភូមិ ទីតាំងសំខាន់ៗ ផ្សព្វផ្សាយតាមឧបករណ៍បំពងសម្លេង | | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x |
| ១៦ | តាមដានការអនុវត្ត និងគាំទ្រយុទ្ធនាការដល់រាជធានី-ខេត្ត ស្រុក ឃុំ ភូមិ | | x | x | x | x | x | x | x | x | x | x | x | | x | | x | | x | | x |
| ១៧ | អញ្ជើញតារាសិល្បៈគ្រូពេទ្យ អ្នកមានឥទ្ធិពល(influencers) ក្នុងតំបន់ថតរូបរបស់គាត់ជាមួយចំណងជើង (with caption) ដោយប្រើសារ "រួមគ្នាទទួលខុសត្រូវទប់ស្កាត់ការចម្លងវីរុសកូវីដ-១៩" (TBD) signs and post them on social media.<br>អញ្ជើញតារាសិល្បៈចូលរួមផ្តល់បទសម្ភាស | | x | x | x | x | x | x | x | x | x | x | x | | x | | x | | x | | x |
| ១៨ | ជំរុញប្រព័ន្ធផ្សព្វផ្សាយចូលរួមផលិតកម្មវិធីផ្សេងៗ ដូចជាកម្មវិធីទូរទស្សន៍ វិទ្យុដែលលើកកម្ពស់ការរស់នៅតាមបែបគន្លងថ្មី | | | | x | | | | | x | x | x | x | | | | | | | | |

| ល.រ | សកម្មភាព | ពេលវេលាផ្សព្វផ្សាយ | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | សីហា | | | | កញ្ញា | | | | តុលា | | | | វិច្ឆិកា | | | | ធ្នូ | | | |
| | | W1 | W2 | W3 | W4 | W1 | W2 | W3 | W4 | W1 | W2 | W3 | W4 | W1 | W2 | W3 | W4 | W1 | W2 | W3 | W4 |
| ១៩ | សហការជាមួយស្ថានីយទូរទស្សន៍វិទ្យុក្នុងតំបន់ដើម្បីផលិតកម្មវិធីផ្សេងៗ | | | | x | | | | | x | x | x | x | x | x | x | x | x | x | x | x |
| ២០ | ការចូលរួមរបស់អ្នកសិល្បៈ ដូចជាការគូរគំនូរ សម្តែង... | | | | X | | | | | x | x | x | x | x | x | x | x | x | x | x | x |
| ២១ | ផលិតចម្រៀង (Create songs or jingles) អំពីតម្រូវការអនុវត្តវិធានការការពារដើម្បីជំរុញការរស់នៅតាមបែបគន្លងថ្មី (MoCult) | | x | x | x | x | x | x | x | x | x | x | x | x | | | | | | | |
| ២២ | បង្កើតការតែងនិពន្ធកំណាព្យ អត្ថបទជំរុញការរស់នៅតាមបែបគន្លងថ្មី (MoCult) | | x | x | x | x | x | x | x | x | x | x | x | x | | | | | | | |
| ២៣ | ផលិត និងដាក់តាំង បដា រូបភាពផ្ទាំងធំ ដាក់បង្ហាញសារតាម LED | | x | x | x | x | x | x | x | x | | | | | | | | | | | |
| ២៤ | ផលិតចែកចាយសម្ភារអនុស្សាវរីយ៍សម្រាប់យុទ្ធនាការដូចជា អាវយឺត មួក កាតាប ពែង ស្ទិកគ័រសម្រាប់បិទរថយន្ត និងសម្ភារផ្សេងៗទៀត | x | x | x | x | x | x | x | x | x | x | x | x | | | | | | | | |
| ២៥ | រៀបចំសកម្មភាព អនឡាយ ជាមួយសិស្សនិស្សិតជំរុញការរស់នៅតាមបែបគន្លងថ្មី | | | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x |
| ២៦ | ជំរុញឲ្យមានការបញ្ចូល ការរស់នៅតាមបែបគន្លងថ្មីក្នុងសៀវភៅសិក្សា | | | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x |
| ២៧ | សកម្មភាពអប់រំផ្សព្វផ្សាយតាមទីតាំងនានា និងសេវាឯកជន វត្តអារាមរោងចក្រ ទីផ្សារ ភោជនីយដ្ឋាន ទីតាំងចំណតរថយន្ត ពីធីផ្សេងៗ | | | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x |

# ៩. ផែនការផ្សព្វផ្សាយសារ

| សេចក្តី | សារ | ពេលវេលាផ្សព្វផ្សាយ | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | សីហា | | | | កញ្ញា | | | | តុលា | | | | វិច្ឆិកា | | | | ធ្នូ | | | |
| | | W1 | W2 | W3 | W4 | W1 | W2 | W3 | W4 | W1 | W2 | W3 | W4 | W1 | W2 | W3 | W4 | W1 | W2 | W3 | W4 |
| ១ | យើងកំពុងស្ថិតនៅក្នុងស្ថានភាពគ្រោះថ្នាក់បំផុត ជាមួយគ្នាភាពធ្ងន់ធ្ងរ ការយល់ឃើញពីហានិភ័យ សាមគ្គីសង្គម | | X | x | x | x | x | x | x | x | x | x | x | | x | | x | | x | | |
| ២ | ការប្រើប្រាស់បច្ចេកវិទ្យាថ្មីដែលមាន | | X | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x |
| ៣ | ទីកន្លែងដែលមានការឆ្លងច្រើន ទីតាំងមានកន្លែងហានិភ័យខ្ពស់ | | X | x | x | x | x | x | x | x | x | x | x | | x | | x | | x | | |
| ៤ | សារសម្រាប់ស្ថានភាពសង្គម និងសាសនាផ្សេងៗ | x | X | x | x | x | x | x | x | x | x | x | x | | | | | | | | |
| ៥ | លើកទឹកចិត្តការធ្វើតេស្តកូវីដ-១៩ ការចាក់វ៉ាក់សាំង ការស្វែងរកការព្យាបាល និងការផ្លាស់ប្តូរឥរិយាបថ | | | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x |
| ៦ | សារសម្រាប់រដូវបុណ្យទាន អាពាហ៍ពិពាហ៍ និងពិធីផ្សេងៗ | | | | | | | | | x | x | x | x | x | x | x | x | x | x | x | x |

# ១០. ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធទី១៖ សម្ភារដែលនឹងផលិតបន្ថែម

### ឡូហ្គោ






### មួក និងអាវយឺត



## មួក និងអាវយឺត



## មួក និងអាវយឺត












រួមគ្នាទទួលខុសត្រូវទប់ស្កាត់ការចម្លងវីរុសកូវីដ-១៩
ត្រូវពាក់ម៉ាស់ជានិច្ចនៅពេលចេញក្រៅផ្ទះ
១១៥ ដោយឥតគិតថ្លៃ

## មួក និងអាវយឺត













បង៉ា


រួមគ្នាទទួលខុសត្រូវទប់ស្កាត់ការចម្លងវីរុសកូវីដ-១៩
ចៀសវាងទៅកន្លែងជួបជុំដែលមានមនុស្សច្រើន
១១៥


រួមគ្នាទទួលខុសត្រូវទប់ស្កាត់ការចម្លងវីរុសកូវីដ-១៩
រក្សាគម្លាត១,៥ម៉ែត្រពីមនុស្សម្នាក់ទៀត
១១៥


រួមគ្នាទទួលខុសត្រូវទប់ស្កាត់ការចម្លងវីរុសកូវីដ-១៩
ត្រូវពាក់ម៉ាស់ជានិច្ចនៅពេលចេញក្រៅផ្ទះ
១១៥


រួមគ្នាទទួលខុសត្រូវទប់ស្កាត់ការចម្លងវីរុសកូវីដ-១៩
ចៀសវាងទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល
១១៥


រួមគ្នាទទួលខុសត្រូវទប់ស្កាត់ការចម្លងវីរុសកូវីដ-១៩
ត្រូវពាក់ម៉ាស់ជានិច្ចនៅពេលចេញក្រៅផ្ទះ
១១៥


រួមគ្នាទទួលខុសត្រូវទប់ស្កាត់ការចម្លងវីរុសកូវីដ-១៩
ចៀសវាងការសន្ទនានៅកៀកគ្នាពេក និងកុំចាប់ដៃគ្នា
១១៥


រួមគ្នាទទួលខុសត្រូវទប់ស្កាត់ការចម្លងវីរុសកូវីដ-១៩
ចៀសវាងការសន្ទនានៅកៀកគ្នាពេក និងកុំចាប់ដៃគ្នា
១១៥


រួមគ្នាទទួលខុសត្រូវទប់ស្កាត់ការចម្លងវីរុសកូវីដ-១៩
លាងដៃឱ្យបានញឹកញាប់ជាមួយទឹកស្អាត និងសាប៊ូ ឬអាកុល
១១៥

Looking for behavior changes






→ **Removing barriers for people so that behaviour change is**

**Easy, Attractive, Social, and Timely (EAST)**